ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខ្សែ ១



ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណើម៉ង្គ

គ្រិ. ឆ្នាំ ១៩៣០

ព. ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-មៅ

# បញ្ជីរឿង


ទំព័រ

១- ប្រសាសន៍លោកគូវែណើរបៀរណោរ៉ាល់ ចំពោះនឹងបណ្ដាស្ត្រីខ្មែរក្នុង ដែនកូសាំងស៊ីនខាងទិសនិរតី ព្រះគ្រូសង្ឃវិជ្ជា តាត អាចារ្យបង្រៀន ភាសាសំស្រ្កឹត នៅសាលាបាលីជាន់ខ្ពស់ អធិប្បាយ . . . . ៥

២- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីបាលី . . . . . , . . . . .

៣- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត) .

— គតិលោក, និង មិលិន្ទបញ្ហា នេះ ( មិនបានចុះក្នុងនេះទេ ព្រោះមាន បោះសៀវភៅដោយឡែកហើយ ) . . . . . .

៤- រឿងមហាភារតយុទ្ធ ព្រះមហាភិរូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ប្រែចេញពីសៀមមកជាភាសាខ្មែរ (តពីខ្សែ ៣ នៃឆ្នាំទី ២) ២៧

# សេចក្ដីរាយការ

អំពីលោកគូវែរណើរហ្សេណេរ៉ាល់ តាម ប៉ាស្គីយេរ អញ្ជើញទៅខេត្តត្រាវិញ (ព្រះត្រពាំង) និងខេត្តសុកត្រាំង (ឃ្លាំង) ជាសាក់ដែនកូសាំងស៊ីន ជាមួយនឹងលោកគូវែរណើរ ដឺឡាកូសាំងស៊ីន និងអស់លោកមន្ត្រីជាំងឯទៀតជាច្រើន មានម៉ាដឺម៉ូអាហ្សែល ការប៉ីឡែស ជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ-កម្ពុជា និងលោកព្រះគ្រូសង្ឃវិជ្ជា ហ. តាត អាចារ្យបង្រៀន នៅសាលាបាលីក្រុងភ្នំពេញទៅជាមួយផង នៅថ្ងៃ ១៧ និង ១៨ ខែសូយេតឆ្នាំ ១៩២៩

ព្រះគ្រូសង្ឃវិជ្ជា ហ - តាត អាចារ្យបង្រៀនភាសាសំស្រ្កឹត

នៅសាលាបាលី ក្រុងភ្នំពេញ អធិប្បាយ

---

ដំណើរនៃលោកគូវែរណើរហ្សេណេរ៉ាល់ ដែលអញ្ជើញទៅក្នុងដែនកូសាំងស៊ីននេះ មានសេចក្ដីដូចម្ដេចខ្លះនោះ ខ្ញុំ (ព្រះគ្រូសង្ឃវិជ្ជា) នឹងរៀបរាប់ឲ្យសព្វគ្រប់តាមដែលបានដឹង និងបានឃើញចំពោះខ្លួនដូចសេចក្ដីតទៅនេះ ។

លោកគូវែរណើរហ្សេណេរ៉ាល់ នៅវេលាមុននឹងចេញទៅកាន់ខេត្តត្រាវិញនិងសុកត្រាំង លោកមកសំចតនៅ ៗ ក្រុងព្រៃនគរ បានមានសំបុត្រ ១ ច្បាប់លេខ ៣៧៧ ចុះថ្ងៃ ១០ សូយេត ១៩២៩ មក លោកឡឺរេស៊ីដង្គ់សុបេរីយើរនៅក្រុងភ្នំពេញ សេចក្ដីថា ខ្លះលោកនឹងអញ្ជើញទៅខេត្តត្រាវិញ និងខេត្តសុកត្រាំង នៅថ្ងៃ ១៧ និង ១៨ សូយេតនេះ ៣ ក្នុងឱកាសដែលលោកអញ្ជើញទៅនោះ លោកនឹងឲ្យប្រជុំអស់ទាំងបណ្ដាជនជាតិខ្មែរ ដែលនៅក្នុងខេត្តនោះ ក្នុងទីអារាមវត្ត (លោកសង្ឃ-

ខ្មែរ) ដើម្បីនឹងបានប្រាប់ពន្យល់ អំពីការបង្កើតនោមុខក្រសួងការ ១ ឈ្មោះអាំងស្ទីទុយពុទ្ធិក គឺមន្ទីរសមាគមអ្នកប្រាជ្ញ ផ្នែកខាងព្រះពុទ្ធសាសនា ។

ជាលោកមានសេចក្តីពេញចិត្តនឹងឲ្យមានភិក្ខុ ១ អង្គ ស្ថិតនៅជាកណ្តាលទីប្រជុំ ហើយនិយាយពន្យល់ដល់លោកសង្ឃផងគ្នា ហើយជាសូមឲ្យលោក ឡឺរេស៊ីដង់ សុប៉េរីយើរ ក្រាបបង្គំទូលព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេច ព្រះ ស៊ីសុវត្ថិ មុនីវង្ស សូមទ្រង់ព្រះមេត្តាប្រោសចាត់ភិក្ខុ ១ អង្គ ដែលចេះបារាំងហើយអាចពន្យល់តាមខ្លួនលោកបាន ។

លោក ឡឺរេស៊ីដង់ សុប៉េរីយើរ ក៏បានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត តាមសេចក្តីខាងលើនេះ ។ ព្រះករុណាជាអម្ចាស់ជីវិតទ្រង់បានចាត់ខ្លួនខ្ញុំ (ព្រះគ្រូសង្ឃវិជ្ជា) ឲ្យទៅជាមួយនឹងអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ តាមសេចក្តីត្រូវការរបស់លោកគូវែរណើរហ្សេណេរ៉ាល់ ។

ថ្ងៃអង្គារ ១០ កើត ខែអសាធឆ្នាំម្សាញ់ឯកស័ក ព.ស. ២៤៧២ត្រូវនឹងថ្ងៃ ១៦ ខែសូយេត ឆ្នាំ ១៩២៩ វេលាម៉ោង ៦ ព្រឹក អ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យនឹងខ្ញុំ បានចេញពីភ្នំពេញទៅដោយរថយន្តរបស់រាជការប្រូតិកតូរ៉ាត់ចំពោះទៅខែត្រត្រាវិញតាមផ្លូវតាកែវ, មាត់ជ្រូក, ឡុង-

ឈៀន, សាដែក, វិញឡុង ដល់ទៅខេត្តត្រាវិញ នៅវេលាម៉ោង ៦ ល្ងាច ។

ថ្ងៃ ពុធ ១៧ សូយេត ១៩២៩ វេលាម៉ោង ៩ ព្រឹក លោកគូវែរ-ណើរ ហ៊្យេណោក៏ល ប៉ាស្គីយេរ បានអញ្ជើញទៅដល់ខេត្តត្រាវិញ ជាមួយនឹងអស់លោកមន្ត្រីបារាំង ដែលជូនដំណើរលោកទៅជា ប្រីនាក់ គឺលោកក្រោហ្វីយ ជាសេក្រទែរហ៊្យេណោក៏ល ១ លោកក្រូបីមែរ ជាគូវែរណើរ ដឹឡាកូសាំងស៊ីន ១ លោកគី ត្រូប ជាចាងហ្វាងក្រសួងរដ្ឋប្រសាសនោបាយនៅកូសាំងស៊ីន ១ លោក បារ៉ូដ៏ ជាអាត់មីនិស្ត្រាទ័រ ដែលលោកបានតែងសៀវភៅ ១ យ៉ាងល្អ និយាយអំពីបណ្ដាជនជាតិខ្មែរនៅកូសាំងស៊ីន១ និងមន្ត្រីបារាំងឯទៀតខ្លះ ។

វេលាដែលលោកគូវែរណើរហ៊្យេណោក៏ល អញ្ជើញទៅដល់ត្រាវិញ លោកក៏បានទទួលគំនាប់និងបដិសណ្ឋារ អំពីសំណាក់នៃអ្នករាជការទាំងអស់មានលោកអាត់មីនិស្ត្រាទ័រជាអធិបតីក្នុងខេត្តនោះជាដើម ដែលបានរៀបចំចាំទទួលនៅទីផ្ទះលោក ។ លុះដល់ម៉ោង ២ រសៀលក្នុងថ្ងៃនោះ លោកបានអញ្ជើញទៅកាន់ទីប្រជុំនៃបណ្ដាជនជាតិខ្មែរ ទាំងព្រះសង្ឃ ទាំងគ្រហស្ថនៅក្នុងទីវត្តកំពង់ធំ ទីកន្លែងដែលប្រជុំនោះគេរៀបជា៣ផ្នែក គឺផ្នែកទី ១ នៅលើយឿនវិហារខាងទិសឧត្តរ សម្រាប់ព្រះសង្ឃគង់បែរមុខទៅខាងជើង ផ្នែកទី ២ គេធ្វើជាបាំក្លាប់ពីយឿនវិហារខាងជើង តែ

ទាបជាងយឿនវិហារបន្តិច មានជណ្តើរឡើងពីខាងជើង សំរាប់ទទួល លោកគូវែរណើរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបារាំងដែលទៅជាមួយ ផ្នែកពី ៣ នៅទីកបទឹងជីខាងជើងបារាំនោះ សម្រាប់បណ្តាកស្ត្រឈរជាជួរ ជាសង្កាត់បែរមុខមកខាងត្បូង ។ ព្រះសង្ឃដែលនិមន្តមកក្នុងទីប្រជុំនោះ មានចំនួនប្រហែលជា ៣០០ រូប ចំណែកខាងគ្រហស្ថប្រមាណជា ៤-៥ រយនាក់ ។

កាលដែល លោក គូវែរណើរហ្សេណេរ៉ាល់ អញ្ជើញទៅដល់ លោកគ្រូ សិរីវិសុទ្ធិវង្ស ជាចៅអធិការវត្តកំពង់ធំ និងលោកគ្រូចៅអធិការវត្តខ្វឹង បានទៅទទួលលោកដល់មាត់ទ្វារកំផែងឧបចារវត្ត ហើយ បាននាំលោកចូលមកដកបជល់ឡើងចូលទៅក្នុងបារាំនោះ បណ្តាជនទាំងអស់កំព្រោកឈរគំនាប់តាមសណ្តាប់ស្រុក ។ ក្នុងឱកាសនោះ លោក គូវែរណើរហ្សេណេរ៉ាល់ បានបែរមុខចំពោះមកកាន់ខ្ញុំ ហើយលោក សម្តែងសេចក្តីគួរសមតាមសណ្តាប់របស់លោក រួចលោកមានប្រសាសន៍ ថា ខ្ញុំមានអំណរពន់ពេកណាស់នឹងព្រះករុណាជាម្ចាស់ជីវិត ព្រះបាទ សម្តេចព្រះ ស៊ីសុវត្ថ មុនីវង្ស ដែលទ្រង់បានចាត់លោកឲ្យមកនេះ រួចលោកអង្គុយលើកៅអីធំកណ្តាល ឯអស់មន្ត្រីបារាំងទាំងឡាយ មាន លោក គូវែរណើរ ដឹឡាកូសាំងស៊ីន ជាដើម ក៏អង្គុយតាមលំដាប់គ្នាក្នុង ទីនោះ ។ នៅពេលនោះ មានលោកភិក្ខុ ១ រូប ចូលទៅឈរចំពោះ

មុខលោកគូវែរណឺរហ្សេណេរ៉ាល់ ហើយសូត្រសេចក្ដីជូនពរសព្វសាធុ-ការ ជាជំនួសតំណាង ព្រះសង្ឃទាំងអស់ ។ សេចក្ដីដែលសូត្រនោះដូចនេះ ៖

សូមបម្រើនពរលោកគូវែរណឺរហ្សេណេរ៉ាល់ និងលោកកូឈួយ ជាម្ចាស់ដែលឥណ្ឌូស៊ិន ។ សូមបម្រើនពរលោក គូវែរណឺរដឺឡាកូ-សាំងស៊ីន ។

អាត្មាភាពជាជំនួសអស់ពពួកសង្ឃ និងបណ្ដាអាណាប្រជានុរាស្ត្រជាខេមរជាតិខេត្តព្រះត្រពាំងសូមសម្ដែងសេចក្ដីកតញ្ញូអរគុណដ៏ខ្ពស់វិសេស ដែលលោកបានអញ្ជើញមកដល់ខេត្តយើងខ្ញុំជាជនបទ មិនគប្បីលោកអញ្ជើញមកបាន នេះពីព្រោះអំណាចសេចក្ដីមេត្តារបស់លោកដល់ខេមរជាតិ និងព្រះពុទ្ធសាសនា ព្រោះហេតុនោះឯង តាំងពីបានដឹងដំណឹងថាលោកអញ្ជើញមក ពពួកសង្ឃនិងគ្រហស្ថមានសេចក្ដីត្រេកអរសាមគ្គីសមកទទួលលោកដោយសេចក្ដីត្រេកអរ ព្រោះដឹងថាលោកអញ្ជើញមកនេះដោយមានប្រាថ្នានឹងបំពេញចិត្តជាតិខ្មែរនៅក្នុងខេត្តនេះ ដែលជាខេត្តជាប់អំពីនគរខ្មែរជាអង្វែងមកយូរហើយៈ យើងខ្ញុំនឹងបានថា ពជការមានសេចក្ដីមេត្តាអាណិតខ្មែរ ថាជាអ្នកប្រព្រឹត្តកេស៊ីស្លូតត្រង់តាមសុចរិតធម៌

សូមបម្រើនពរលោក ពពួកសង្ឃទាំងឡាយមានភ័ព្វល្អប្រមាណជាពីរឆ្នាំមកហើយ ដោយមានលោក អាត់មីនិស្ត្រាទ័រ ជាចៅ

ហ្វាយខេត្ត លោកមេម្ចាស់ស្រ្គោះដល់ពួកយើងបីដូចជាឪពុកនិងកូន គឺលោកឲ្យសង់សាលារៀនក្នុងវត្តឲ្យកូនខ្មែររៀន ព្រោះជាកូនខ្មែរចូលចិត្តរៀនតែក្នុងវត្ត ។ មួយទៀតលោកមិនប្រកាន់ខ្លួន យកសុភាសិតវាចាដ៏ពិរោះ ប្រាប់ពន្យល់ការដែលមានប្រយោជន៍ ហើយលោកបើកច្បាប់ដល់ពួកយើង ថាបើមានសេចក្តីសង្ស័យនឹងការអ្វី ឲ្យទៅសួរលោកៗក៏មានចិត្តត្រេកអរប្រាប់ដោយស្រួល មិនតែប៉ុណ្ណោះ នៅមានការដែលលោកធ្វើឲ្យមានប្រយោជន៍ ដល់ជាតិខ្មែរជាច្រើនទៀតគណនាពុំបាន ។ សម័យនេះ ពួកយើងខ្ញុំមានភ័ព្វ ដោយអំណាចមេត្តារបស់លោកគូវែរណើរហ្សេណេរ៉ាល់ ទើបបានចូលមកបម្រើនពរ នឹងគោរពប្រតិបត្តិសូមលោកមេត្តាជួយបំភ្លឺឲ្យបានក្នុងព្រះពុទ្ធសាសនា នឹងការឯណាជាប្រយោជន៍ដល់អាណាប្រជានុរាស្ត្រខ្មែរ ត្បិតអីជាតិខ្មែរមានសេចក្តីខ្លៅល្ងង់ និងក្រីក្រលំបាកជាងជាតិដទៃ ការដែលយើងសូមជូនខក្នុងខាងក្រោមនេះ សង្ឃឹមលើលោកជាអ្នកតំណាងរាជការនៅក្នុងដែននេះជាអង្វែងមកហើយ បានប្រសប់ការជ្រួតជ្រាបពិធីគ្រប់ជាតិក្នុងឥណ្ឌូ-ស៊ីនសមជាអ្នកជំនួសតំណាងរាជការបារាំងសែស ។

ខ ទី ១- យើងខ្ញុំ សូមពួកសង្ឃទាំងអស់រួចពន្ធរាជការស្រឡះ ។

ខ ទី ២- យើងខ្ញុំសូមពួកសង្ឃទាំងអស់រួចអំពីធ្វើទាហាន ។

ខ ទី ៣- សូមអំពីធ្វើឈាបនកិច្ចសាកសពស្រស់ ។

សូមលោកកែច្បាប់បន្ទូរឲ្យធ្វើបានដោយងាយ ត្បិតអីពួកខ្មែរច្រើនខ្សោយល្ងង់ក្រលំបាក ហើយនៅឆ្ងាយអំពីក្រុងផង មិនអាចធ្វើតាមច្បាប់អំពីមុននោះបាន ពីព្រោះធ្វើច្បាប់ច្រើនយ៉ាង ហើយដាច់បង់សោហ៊ុយនិងយូរក្រុបាន ហេតុត្បិតនៅឆ្ងាយអំពីលោកចៅហ្វាយស្រុក មានសេចក្ដីលំបាកវេទនាណាស់ ។

១វិញទៀត លោកបានជ្រាបសព្វគ្រប់ប្រការអំពីលទ្ធិគ្រប់ជាតិនៅក្នុងកូសាំងស៊ីន សូមលោកលៃលកកិច្ចយ៉ាងណា ដើម្បីសង្គ្រោះដឹកនាំខេមរជាតិឲ្យបានធ្វើជានាហ្មឺន ដោយងាយផង យើងខ្ញុំសូមជ្រកកោនក្រោមម្លប់យកលោកជាទីពឹង ត្បិតលោកមានសេចក្ដីមេត្តាអាណិតជាតិខ្មែរដោយក្រៃពេក ។

ពពួកសង្ឃនិងគ្រហស្ថ ដែលមានសាមគ្គីសស្មោះសរ បានមកសន្និបាតប្រជុំព្រមក្នុងអាកាសកំពង់ធំនេះថា សូមឧទ្ទិសដល់ទេវតាឥន្ទ-ព្រហ្ម សូមបំរើននូវសុខសួស្ដី ដល់លោក គូវែរណើរហ៊្សែណាល់ និង លោកសេក្រែទែរហ៊្សែណាល់ ឥណ្ឌូស៊ីន លោក គូវែរណ័ ដឺឡា កូសាំងស៊ីន និងលោកអាត់មីនិស្ត្រាទ័រ ជាម្ចាស់ខេត្ត និងសូមឲ្យបានចម្រើន អាយុ វណ្ណ សុខ ពល ដល់លោកសព្វកាលតទៅ ។

សូមសេចក្ដីចម្រើនបរមានដល់ក្រុងបារាំងសែស ដែនឥណ្ឌូស៊ីន និងកូសាំងស៊ីន ឲ្យបានសេចក្ដីសុខ ជាថាវរមាំមួនរៀងរាបដរាបអស់

កាលជាអន្លង់តទៅ ។

ទើបមានសេក្រទែរជាតិខ្មែរ ១ នាក់ឈ្មោះ សៅ សូត្រប្រែពីខ្មែរជាបារាំងក្នុងកាលជាល់ជាប់គ្នាមក ។

កាលដែលសូត្រចប់ហើយ លោកគូវែរណើរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបារាំងទាំងអស់ ក៏ទទួលពរសព្ទសាធុការនោះដោយហត្ថប្បហាសញ្ញា គឺទះដៃទទួលអំណរព្រមគ្នា ទើបលោកគូវែរណើរហ្សេណេរ៉ាល់ ក្រោកឈរឡើង ហើយថ្លែងសេចក្តីសារសព្ទតបទៅ-វិញថា ខ្លួនខ្ញុំមានសេចក្តីត្រូវការនឹងសម្តែងឲ្យជាក់ស្តែងដល់អស់អ្នកទាំងឡាយដែលជាខេមរជាតិទាំងអស់ ខ្ញុំមិនមែនជាអ្នកមិនយកចិត្តទុកដាក់មិនទទួលធុរៈនឹងបណ្តាជនជាតិខ្មែរនោះទេ ព្រោះខ្លួនខ្ញុំមានសេចក្តីត្រូវការប្រាថ្នានឹងរាប់អាន ឬយកចិត្តទុកដាក់ចំពោះបណ្តាជនដែលនៅក្នុងប្រទេសឥណ្ឌូចិនទាំងអស់ស្មើៗ គ្នា ។ ម្យ៉ាងទៀតឯការសុំទាំង ៣ យ៉ាងនោះ ជាធុរៈនៅលើលោកគូវែរណើរ ដឺឡាកូសាំងស៊ីន លោកនឹងគិតលៃលកជំនុំឲ្យក្នុងកាលជាខាងក្រោយ ។

លោកគូវែរណើរហ្សេណេរ៉ាល់ បានតបសេចក្តីដូចនេះរួចហើយ ក៏អញ្ជើញចូលទៅក្នុងវិហារ ហើយឲ្យព្រះសង្ឃ និងគ្រហស្ថទាំងអស់ចូលទៅជួបជុំក្នុងទីព្រះវិហារ ខ្លួនលោកចូលទៅឈរកណ្តាលចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ហើយបានប្រគល់ប្រសាសន៍ពត៌មានរបស់

លោកមកខ្ញុំ ដើម្បីឲ្យថ្លែងពន្យល់សេចក្តីនោះជាភាសាខ្មែរ ប្រគេនដំណឹងព្រះសង្ឃនិងជូនដំណឹងដល់គ្រហស្ថទាំងអស់ ជាជំនួសតំណាងខ្លួនលោក ។

សេចក្តីដែលខ្ញុំបានថ្លែងពន្យល់ក្នុងទីប្រជុំនោះ ដូចនេះ ៖

ព្រះករុណាគ្រប់ព្រះអង្គ និងអស់លោកអ្នកទាំងឡាយ ឥឡូវនេះ លោកគូវែរណឺរហ្សេណេរ៉ាល់ បានចាត់ខ្ញុំឲ្យជូនដំណឹង ដូចសេចក្តីខាងក្រោមនេះ :

លោក គូវែរណឺរហ្សេណេរ៉ាល់ លោកបានយល់ព្រម ដោយពេញចិត្ត តាមលោក គូវែរណឺរដឺឡាកូសាំងស៊ីន ដែលបានគិតធ្វើប្រយោជន៍ឲ្យមានដល់ជនជាតិខ្មែរ ក្នុងដែនកូសាំងស៊ីននេះ គឺ :

អំពីដំណើរដែលលោកគូវែរណឺរ ដឺឡាកូសាំងស៊ីន បានបញ្ជូនលោកសង្ឃ ៣០ រូបក្នុង ១ ឆ្នាំៗ ទៅឯក្រុងភ្នំពេញ ដើម្បីរៀនមើលរៀនសរសេរ និងរៀននិយាយពាក្យខ្មែរ ឲ្យត្រឹមត្រូវដោយហ្មត់ចត់ព្រមទាំងរៀនវិជ្ជាខាងព្រះពុទ្ធសាសនាផង ដើម្បីនឹងត្រឡប់មកបង្រៀនក្នុងវត្តរៀងខ្លួនតទៅទៀត ។

អំពីដំណើរដែលលោកគូវែរណឺរ ដឺឡាកូសាំងស៊ីន បានតម្រូវឲ្យខេត្រខ្មែរទាំងអស់ ជាវសៀវភៅទស្សនាវដ្តី "កម្ពុជសុរិយា" មកទុកដើម្បីប្រយោជន៍ដល់ព្រះភិក្ខុសង្ឃ ឬគ្រហស្ថដែលចង់ចេះបង់ដឹង និង

បានមើលសេចក្ដីដែលជាខ្លឹមសារ ។

ទីងអំពីដំណើរលោក គូវែរណឺរ ជឺឡាកូសាំងស៊ីន បានឲ្យដំបូន្មាន ដើម្បីឲ្យប្រតិបត្តិតាមទំនៀមទម្លាប់របស់ស្រុក និងតាមច្បាប់ក្នុងព្រះពុទ្ធសាសនារបស់ជាតិខ្មែរ ។

ក្នុងក្រុងកម្ពុជាកដការបារាំងសែស បានបង្កើតសាលាបាលីនិងព្រះរាជបណ្ណាល័យជាយូរឆ្នាំមកហើយ នៅព្រះរាជបណ្ណាល័យគេបានប្រមូលផ្ដុំនូវគម្ពីរដីកាផ្សេង ៗ ហើយបានចាត់ការបោះពុម្ពជាសៀវភៅខ្មែរដ៏ច្រើន ៗ

ដើម្បីកុំឲ្យភាសាខ្មែរបាត់បង់ទៅ និងកុំឲ្យវិប្បលាសប្រែប្រួលទៅ ដើម្បីឲ្យបានព្រះពុទ្ធសាសនាគង់នៅជាដរាបរៀងទៅ ហើយឲ្យបានអស់ទាំងស្រុក ក្នុងប្រទេសឥណ្ឌូស៊ីនបារាំងសែសនេះ ដែលកាន់ព្រះពុទ្ធសាសនាបែកខាងហីនយាន ធ្វើការរួបរួមគ្នានោះ លោកគូវែរណឺរហ្សេ-ណេរ៉ាល់ តាំងបង្កើតនូវមុខក្រសួងការមួយឡើង ដែលឲ្យឈ្មោះថា "មន្ទីរសមាគមអ្នកប្រាជ្ញ បែកខាងព្រះពុទ្ធសាសនា ក្នុងប្រទេសឥណ្ឌូស៊ីនបារាំងសែស" មន្ទីរនេះត្រូវចាត់ការដូចមានខាងក្រោយគឺ :

១- ត្រូវបោះពុម្ពព្រះត្រៃបិដកឲ្យចប់ជាអក្សរជ្រៀង ដើម្បីឲ្យបានមាន ១ ចប់ៗគ្រប់វត្ត ។

២- ត្រូវប្រែព្រះត្រៃបិដកពីបាលីមកជាភាសាខ្មែរ ដើម្បីឲ្យបានអ្នកបួសទាំងអស់ យល់នូវធម៌អាថ៌ដែលសុត្រគាល់ថ្ងៃ ។

៣- ត្រូវបោះពុម្ពសព្វវចនខ្មែរ ១ ឡើង ដើម្បីឲ្យបានយល់ស្គាល់ច្បាស់នូវពាក្យសម្ដីដែលយើងស្ដី ហើយដើម្បីនឹងឲ្យបានសរសេរដោយត្រឹមត្រូវ និងតែងសេចក្ដីផ្សេងៗ ដោយគ្រោះក្សាយផង ។

៤- ត្រូវតាំងបង្កើតសាលារៀនក្នុងវត្តទាំងឡាយ ដើម្បីឲ្យលោកសង្ឃបង្រៀនវិជ្ជាបាលីនិងព្រះពុទ្ធសាសនា បើដូចនេះឃើញថា ពពួកសង្ឃនឹងបានទៅជាអ្នកប្រាជ្ញដូចកាលអំពីដើមវិញ ហើយនឹងបានជាទីគោរពនៃបណ្ដាគ្រហស្ថទាំងឡាយ ។

៥- ត្រូវតាំងបង្កើតកន្លែងប្រជុំ សម្រាប់ទាហានក្រុមពិជ័យសង្គ្រាមនិងក្រុមរក្សាស្រុក នៅកន្លែងនោះត្រូវឲ្យមានសៀវភៅផ្សេងៗ ជាអក្សរខ្មែរ ធ្វើដូចនេះឃើញថាពពួកទាហានទាំងនោះ នឹងមិនតាំងចិត្តថាខ្លួនជាមនុស្សឯកឯងឡើយ ។

៦- ត្រូវធ្វើដូចម្ដេច ឲ្យបានពុទ្ធសាសនិកជនទាំងឡាយ អាចធ្វើនូវបុណ្យទាននិងការកុសលផ្សេងៗ តាមកម្លាំងសទ្ធាបានដោយស្រួល ឯលក្ខណបញ្ញត្តិរបស់កដការទាំងប៉ុន្មាន ត្រូវប្រែមកជាភាសាខ្មែរទាំងអស់ផង ។

លោក គូវែរណើរហ្សេណេរ៉ាល់ ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ មុនីវង្ស ព្រះចៅក្រុងកម្ពុជា ព្រះបាទសម្ដេចព្រះស៊ីសុវាងវង្ស ព្រះចៅក្រុងហ្លួងព្រះបាង លោក គូវែរណើរ ដឺឡាកូសាំងស៊ីន

លោក ឡឺរេស៊ីដង្ក សុប៉េរីយើរ ក្រុងកម្ពុជា និង ក្រុងឡាវ ព្រមទាំងមន្ត្រីធំៗ ក្នុងក្រុងភ្នំពេញនិងក្រុងឡាវ ទីង ទទួលកិច្ចជួយឧបត្ថម្ភមន្ទីរ សមាគមអ្នកប្រាជ្ញ ប៉ែកខាងព្រះពុទ្ធសាសនា ក្នុងប្រទេសឥណ្ឌូចិន ជាពិសេសនេះ ។

លោក គូវែរណឺរហ្សេណេរ៉ាល់ លោកបញ្ចប់សេចក្តីត្រង់នេះហើយ សូមឲ្យពរសព្វសាធុការដល់ព្រះសង្ឃគ្រប់អង្គ សូមឲ្យបានចម្រើនដល់វត្តទាំងអស់ សូមឲ្យកើតមានជាហោសៀវភៅ រៀបចំតាមក្បួនខ្នាតឡើង ហើយសូមឲ្យសាធារណៈទីងឧបាសកឧបាសិកា ទទួលកាន់តាមធម៌វិន័យនិងតាមដំបូន្មាន ព្រមទាំងទទួលគោរពកោតខ្លាចនូវធម៌និងសីលរបស់ព្រះសង្ឃគ្រប់អង្គ ។

ចំពោះទីងឧបាសកឧបាសិកាវិញ លោក គូវែរណឺរហ្សេណេ-រ៉ាល់ សូមឲ្យពរសព្វសាធុការ សូមឲ្យបានប្រកបដោយសេចក្តីសុខគ្រប់ប្រការ ក្នុងការដែលគោរពប្រតិបត្តិតាមធម៌វិន័យ របស់ព្រះសម្មាសម្ពុទ្ធ ហើយសូមឲ្យអ្នកទាំងអស់បានចម្រើននូវផលដំណាំផ្សេងៗ មានស្រូវជាដើមផង ដើម្បីជារង្វាន់ខាន់ទៅដល់សេចក្តីព្យាយាមរបស់អ្នកទាំងអស់គ្នា ។

ប្រសាសន៍ពតិមានរបស់លោក គូវែរណឺហ្សេណេរាល់ ចប់តែប៉ុណ្ណេះ ។

(តាមសេចក្តីពិតមានខាងលើនេះ គេនឹងអាចឃើញបានថា ស-ភាពនៃគំនិតឬកិច្ចការរបស់ជាតិខ្មែរទាំងឡាយ នៅក្នុងដែនកូសាំងស៊ីន នឹងប្រព្រឹត្តទៅតាមទំនងនៃការងារ ដែលលោក គូវែរណើរហ្សេណេរ៉ាល់ បានកំណត់ទុក ដើម្បីនឹងធ្វើទៅក្នុងខាងមុខ) ។

កាលដែលខ្ញុំបានថ្លែងពន្យល់សេចក្តីនោះចប់ហើយ ព្រះសង្ឃទាំងអស់គឺមានសេចក្តីត្រេកអរគ្រប់អង្គ ហើយបញ្ចេញនូវឧទានវាចាថា: សាធុ! ព្រមគ្នាទាំងអស់ ។

លុះរួចកិច្ចក្នុងទីប្រជុំនេះហើយ លោក គូវែរណើរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបារាំងទាំងអស់ ព្រមទាំងម៉ាដឹម៉ូស ហ្សែលការប៉ុម្សស និងខ្លួនខ្ញុំផង បានចេញពីទីក្រុងកំពង់ធំ ហើយឡើងរថយន្តឆ្ពោះតម្រង់ទៅសាលុប (កប៉ាល់តូច) នៅកំពង់មាត់ភ្នាត (កំពង់នេះយួនហៅកូក្វាន) ក្នុងខេត្តត្រាវិញ កាលទៅដល់ទីកំពង់នេះ ឃើញអស់ពួកមន្ត្រីយួនរៀបចាំទទួលលោក គូវែរណើរហ្សេណេរ៉ាល់ ជាការរុងរឿង មានមនុស្សមើលដេរដាសរង់ចាំមើល ច្រើនតែជាតិយួន ជាតិខ្មែរមានបន្តិចបន្តួច ។

លុះចុះសាលុបនោះព្រមគ្នាហើយ សាលុបនោះក៏បើកចេញចំពោះទៅកាន់កំពង់ពាមសែន (យួនហៅថា ដៃឌាយ) ក្នុងខេត្តសុកត្រាំង កាលសាលុបដល់ទៅហើយ ចូលចតជិតទីផែនៅទីនោះ ឃើញលោកអាត់មីនិស្ត្រាទ័រនៅខេត្តសុកត្រាំង អញ្ជើញមកនៅចាំទទួលលោកគូវែរ-

ណើរហ្សេណេរ៉ាល់ នៅទីផែនោះ ជាមួយនឹងមន្ត្រីយួនជាច្រើននាក់ ។ ឯរបៀបដែលរៀបទទួលនៅទីផែនោះជាការអធិកអធមណាស់ គឺមានគ្រឿងតាំង ១ គ្រឿងរៀបចំពាក់កណ្ដាលផែ ហើយមានក្មេងយួននៅសងខាងទិងចងទង់ជ័យខ្វាត់ខ្វែង ព្រមទាំងគ្រឿងប្រដាប់ផ្សេង ៗ មានលំពែងជាដើម ជាប្រដាប់សម្រាប់ហែរបស់ជាតិយួន ។ កាលសា-លុបចូលចតភ្ជាម គឺនាំគ្នាអុជផាវទិងលេងភ្លេងផង ឮសូរសព្ទគ្រហឹងអឺងកាប់ លុះស្ងប់ស្ងាត់ផាវហើយ ទើបលោកគូវែរណើរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបារាំងទាំងអស់ឡើងតាមជាលំដាប់ទៅ ឯពួកយួនអ្នកក្មេងទិងអ្នកកាន់គ្រឿងប្រដាប់សម្រាប់ហែ ក៏លេងភ្លេងដង្ហែតាមក្រោយទៅ មានពួកមនុស្សជាច្រើនតាន់តាប់មីរជេរដាសឈរចាំមើល ។ លុះទៅដល់កន្លែងរថយន្តទើបលោកគូវែរណើរ ហ្សេណេរ៉ាល់ និងលោកគូវែរណើរដឺឡាកូសាំងស៊ីន លោកឡើងរថយន្ត ១ ខាងមុខបំផុតនោះទៅ ឯអស់លោកមន្ត្រីឯទៀតនិងខ្ញុំ ក៏ឡើងរថយន្តហើយចេញទៅតាមលំដាប់លំដោយគ្នាឆ្ពោះដំរង់ទៅស្រុកត្រាំង ចេញពីពាមសែនទៅចំនួន ១៩ គីឡូម៉ែត្រក៏ដល់ទៅស្រុកត្រាំង នៅវេលាម៉ោង ៦ ល្ងាច ។

កាលដល់ទៅស្រុកត្រាំង ឃើញរបៀបដែលរៀបទទួលតាមផ្លូវនោះជាការឧត្ដមក្រៃពេក តាមសមគួរដល់សក្ដានុភាពរបស់លោកគូវែរណើរហ្សេណេរ៉ាល់ មានមនុស្សទាំងជាតិខ្មែរ ជាតិយួន ដែលឈរចាំមើល

នោះត្រៀបត្រាគមសងខាងផ្លូវ ចំនួនប្រមាណជា ៤-៥ រយម៉ែត្រ ដរាប ដល់ទៅទីផ្ទះលោកអាត់ម៉ីនិស្ត្រាទ័រ ។ លោកគូវៃរណើរយេរណាក់ល់ កាលដល់ទៅទីផ្ទះលោកអាត់ម៉ីនិស្ត្រាទ័រនោះហើយ ក៏បានទទួលគំនាប់ និងបដិសណ្ឋារ អំពីសំណាក់លោកអាត់ម៉ីនិស្ត្រាទ័រនៅខេត្តនោះ និង បណ្ដាអ្នករាជការជាតិខ្មែរ និងជាតិយួនទាំងអស់ តាមទំនៀម ហើយ លោកសម្រាកក្នុងវេលាយប់នោះ ។

លុះដល់ព្រឹកឡើងថ្ងៃ ១៣ ខែស្សូយេត ឆ្នាំ ១៩២៩ វេលាម៉ោង ៨ ព្រឹក លោកគូវៃរណើរហៀរណាក់ល់ និងអស់លោកមន្ត្រីបារាំងទាំងអស់ បានអញ្ជើញទៅវត្តឃ្លាំង ដើម្បីនឹងបានជួបជុំជាមួយនឹងអស់បណ្ដាជនជាតិខ្មែរ ទាំងព្រះសង្ឃទាំងគ្រហស្ថ ។ នៅវត្តឃ្លាំងនោះ គេរៀបចំហាំទទួលលោកគូវៃរណើរហៀរណាក់ល់នៅលើសាលា ១ ជាខាងជើងវិហារ សាលានោះរៀបនឹងសង់ថ្មីស្អាតបាត មានទំហំទទឹងប្រ-មាណជាង ១០ ម៉ែត្រ បណ្ដោយប្រមាណជាង ៣០ ម៉ែត្រ គេរៀបទីសម្រាប់ព្រះសង្ឃឱ្យគង់នៅខាងត្បូង ទីសម្រាប់លោកគូវៃរណើរហៀរ-ណាក់ល់នូវអស់លោកមន្ត្រីបារាំងនៅជាកណ្ដាល បែរមុខចំពោះទៅខាងព្រះសង្ឃ ទីសម្រាប់បណ្ដាជនជាតិខ្មែរនៅខាងជើង ។ លោកសង្ឃដែលនិមន្តមកក្នុងទីប្រជុំនោះប្រមាណជា ១០០ រូប បំណែកខាងគ្រហស្ថទាំងមន្ត្រីទាំងរាស្ត្រ ប្រមាណជាជាង ២០០ នាក់ សុទ្ធតែជាតិខ្មែរទាំង

អស់ ឥតមានលាយប្រឡំដោយជាតិយួនឡើយ ។

កាលដែលលោកគូវែរណឺរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបា-រាំងទាំងអស់អញ្ជើញដល់ទៅហើយឡើងទៅសាលាបានអង្គុយនៅលើកៅអីរួចស្រេចហើយ ។ លោកចៅហ្វាយខេត្ត ( យួនហៅថា ទុងភូ ) ឈ្មោះ អ៊ឹម ជ.តិជាខ្មែរ បានសូត្រសេចក្ដីជូនពរសព្ទសាធុការ ជាភាសាបារាំងចំពោះមុខលោកគូវែរណឺរហ្សេណេរ៉ាល់ ជាជំនួសតាងនាមនៃបណ្ដាជនជាតិខ្មែរទាំងអស់ ៖

សេចក្ដីដែលសូត្រនោះប្រែមកជាភាសាខ្មែរដូចខាងក្រោមនេះ ៖

សូមជម្រាបលោកគូវែរណឺរហ្សេណេរ៉ាល់ សូមជម្រាបលោកគូវែរណឺរ សូមជម្រាបលោកស្រី សូមជម្រាបអស់លោកទាំងអស់ ។

ដោយខ្លួនខ្ញុំបាទ ជាអ្នករាជការខ្មែរក្នុងដែនកូសាំងស៊ីន ខ្ញុំបាទសូមថ្លែងសេចក្ដីតាងនាមបណ្ដាមនុស្ស ជាតិជាមួយទាំងអស់ក្នុងខេត្តស្រុកត្រាំង ដើម្បីជម្រាបជូនពរសព្ទសាធុការដល់អស់លោកដែលបានអញ្ជើញមកក្នុងទីនេះ ។

គឺជាដំបូងបង្អស់ដែលមានមន្ត្រីសក្ដិធំដូចយ៉ាងលោកនេះ ឈានដើរចូលក្នុងវត្តខ្មែរ ។

ការដែលលោកអញ្ជើញមកនេះ មិនមែនជាទម្លាប់ធ្លាប់មានមកក្នុង•

ពន្យារពេលគ្រាមុនៗឡើយ ហើយថ្ងៃខែនិងពេលវេលាដែលលោក អញ្ជើញមកនេះ នឹងបានជាប់ជានិច្ច ក្នុងរឿងរ៉ាវ និងក្នុងប្រវត្តិនៃ ជាតិខ្មែរទាំងអស់ ។

យើងខ្ញុំទាំងអស់គ្នា មានសេចក្ដីសាទរសោមនស្សដោយក្រៃលែង អំពីសេចក្ដីស្រឡាញ់យ៉ាងវិសេស ដែលលោកធ្វើឲ្យឃើញជាក់ស្ដែង ឡើងចំពោះអស់យើងកលគ្នា យើងសូមអរគុណនឹងលោកជាបំផុតដោយ ស្មោះពីដួងចិត្តយើងទាំងឡាយ ។

ដែលលោកអញ្ជើញមកកាន់ទីនេះ មិនមែនគ្រាន់តែនាំឲ្យរឹតតែមាំ ដល់គំនិតដែលក្រុងបារាំងសែសតាំងប្ដេជ្ញា ថាធ្វើប្រយោជន៍ឲ្យដល់ជាតិ ខ្មែរយើង ដោយឲ្យចំណេះវិជ្ជាឡើយ គឺថែមទាំងធ្វើឲ្យឃើញថាស្រុក បារាំងសែសនេះដូចជាមាតា តែងតែខំធ្វើការដើម្បីប្រយោជន៍ដល់កូន ទាំងខាងភោគសម្បត្តិ ទាំងខាងវិជ្ជាសម្បត្តិ ។

បពិត្រលោកគូវែរណឺរហ្សេណេរ៉ាល់ សាសនានេះជាប្រធាន ធំបំផុតរបស់យើងតាំងអំពីដើមរៀងមក ជាតិខ្មែរនីមួយៗដែលជាអ្នក កាន់តាមគន្លងប្រវេណីរបស់ស្រុករៀងមកនេះ ដើមដំបូងត្រូវរៀនយក លក្ខណបញ្ញត្តិផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ហើយបួសកាន់ភេទជា បព្វជិត តាមកាលសម័យជាមុន ដែលនឹងចុះកាន់ការដែលប្រព្រឹត្តទៅ ក្នុងជាតិ ។

យើងទាំងអស់គ្នា សូមជម្រាបលោកគូវែរណឺហ្សេណេរ៉ាល់ថាយើងមានសេចក្ដីសោមនស្សដ៏ធំទូលាយ ដោយបានឃើញលោកជាមន្ត្រីសក្ដិធំ ដែលជាតំណាងព្រះមហានគរបារាំងសែសមកក្នុងប្រទេសឥណ្ឌូស៊ិនបានអញ្ជើញមកកាន់ទីអស់យើងខ្ញុំទាំងឡាយនេះ ហើយយើងខ្ញុំមានសេចក្ដីជ្រះថ្លានឹងសូមជម្រាបអញ្ជើញជាភ្ញៀវរបស់យើងខ្ញុំ ។

យើងសូមអរគុណដល់អ្នកស្រី ការប៉ុឡែសផង អំពីសេចក្ដីនឿយព្រួយក្នុងការដែលអ្នកស្រីបានខិតខំសង្ហាត ឲ្យបានមានសតិបញ្ញាដល់លោកសង្ឃ ២៤ អង្គក្នុងដែនកូសាំងស៊ិន ដែលរកការបានចេញសោហ៊ុយឲ្យទៅនៅរៀនឯស្រុកភ្នំពេញ ។

ឥឡូវនេះខ្ញុំសូមគោរពដោយកិច្ចដ៏សុភាពបំផុត និងសូមអរគុណដល់លោកជាថ្មីម្ដងទៀត ។ បពិត្រលោកគូវែរណឺរហ្សេណេរ៉ាល់ សូមលោកជឿថា យើងទាំងអស់នេះជាមនុស្សមិនភ្លេចគុណ ចំពោះមហានគរដែលមានលោកជាតំណាងយ៉ាងវិសេស ១ ក្នុងចំណោមអស់លោកដែលជាតំណាងក្រុងបារាំងសែសទាំងប៉ុន្មាន ។

សូមសេចក្ដីចម្រើន មានដល់ព្រះមហានគរបារាំងសែស ។

សូមសេចក្ដីចម្រើន មានដល់ឥណ្ឌូស៊ិន ។

កាលដែលចៅហ្វាយខេត្ត អ៊ឹម ថ្លែងសេចក្ដីជូនពរសព្វសាធុការចប់ហើយ លោកគូវែរណឺរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបារាំង

ទាំងអស់ ក៏ទទួលពរសព្ទសាធុការដោយហត្ថប្រាសញ្ញាព្រមគ្នា ទើបលោកក្រោកឈរឡើង ហើយសារសព្ទថ្លែងសេចក្តីតបទៅវិញដោយមាត់ទទេ ។ ឯសេចក្តីដែលលោកឆ្លើយតបមកវិញនោះ ក៏ដូចគ្នានឹងសេចក្តីដែលលោកឆ្លើយតបឯខែត្រត្រាវិញដែរ ប្លែកគ្នាបន្តិចបន្តួច ហើយឥតមានឆ្លើយតបអំពីការសុំទាំង៣យ៉ាងនោះទេ ព្រោះក្នុងសេចក្តីដែលសូត្រជូនពរក្នុងខែត្រនេះ មិនមាននិយាយដល់ការសុំទាំង ៣ យ៉ាងនោះឡើយ ។ ទើបលោកគូវែរណឺរហ្សេណេរ៉ាល់ បានប្រគល់ប្រសាសន៍-ពណ៌នារបស់លោកមកខ្ញុំ ថ្លែងពន្យល់ដល់ព្រះសង្ឃនិងបណ្តាជនជាតិខ្មែរទាំងអស់ ដូចគ្នានឹងសេចក្តីដែលបានថ្លែងពន្យល់ក្នុងទីប្រជុំឯខែត្រត្រាវិញ ។

កាលដែលខ្ញុំថ្លែងពន្យល់សេក្តីនោះហើយ លោកចៅអធិការ លង់ នៅវត្តឃ្លាំង ក្រោកឈរឡើងហើយសូត្រសេចក្តីទទួលអំណរជាភាសាខ្មែរ ជាតំណាងនាមព្រះសង្ឃទាំងអស់ក្នុងទីចំពោះមុខលោកគូវែរណឺរហ្សេណេរ៉ាល់ ។

សេចក្តីដែលលោកសូត្រដូចនេះ ៖

យើងទាំងអស់គ្នា បានដឹងជាប្រាកដថាៈលោកគូវែរណឺរហ្សេណេរ៉ាល់ លោកមានសេចក្តីស្រឡាញ់ប្រទេសឥណ្ឌូស៊ីននិងបណ្តាជន ដែលនៅក្នុងប្រទេសនេះណាស់ ។ លោកបានរមិលមើលជានិច្ចដល់ការសុខ

ទុក្ខ និងដល់ការសួស្ដីជ័យមង្គលគ្រប់យ៉ាងរបស់បណ្ដាជនទាំងអស់គ្នា ។

ក្នុងថ្ងៃនេះយើងអាចនឹងបញ្ជាក់បាន ដល់លោកគូវែរណើរហ្សេណេរ៉ាល់ថា ដំណើរដែលលោកទើបនឹងឡើងដល់យើងអម្បាញ់មិញនេះ ធ្វើឲ្យយើងបានសេចក្ដីត្រេកអរសោមនស្សពន់ពេកណាស់ យើងជាប់ជំពាក់នៅក្នុងឧបការគុណរបស់លោកជានិច្ច អំពីកិច្ចដែលលោកបានជ្រោមជ្រែងយើងឲ្យទៅជាអ្នកចេះដឹងច្រើនឡើង ហើយយើងឥតមានភ្លេច ១ វេលាឡើយ ថាដោយសារលោក បានជាយើងអាចនឹងរចនានូវស្មារតីរបស់យើងឲ្យប្រពៃឡើងបាន ។

យើងសូមអរគុណដល់លោកគូវែរណើរ ដឹឡាកូសាំងស៊ុង អំពីការទាំងប៉ុន្មានដែលបានធ្វើហើយ ព្រមទាំងអស់លោកទាំងឡាយ ដែលបានចូលជួយក្នុងកិច្ចសម្រួលការរៀនសូត្រ របស់ជាតិខ្មែរក្នុងដែនកូសាំងស៊ុនឲ្យចម្រើនឡើង ។

កាលដែលលោកចៅអធិការ លង់ បានសូត្រសេចក្ដីទទួលអំណរចប់ហើយ ខ្ញុំក៏បានសូត្រសេចក្ដីរបស់លោកចៅអធិការ លង់ នោះ ១ ចប់ទៀត តែប្រែជាភាសាបារាំងជូនលោកគូវែរណើរហ្សេណេរ៉ាល់ ឲ្យលោកយល់សេចក្ដីបាន ។

លុះរួចកិច្ចក្នុងទីប្រជុំនោះហើយ លោកគូវែរណើរហ្សេណេរ៉ាល់ និងអស់លោកមន្ត្រីបារាំងទាំងអស់ ចុះពីទីសាលានោះហើយចូលទៅមើល

ក្នុងទីព្រះវិហារ ព្រោះវិហារនោះជាទីស្អាតបាតល្អ ប្រកបដោយក្បាច់របនាផ្សេងៗដ៏ច្រើន ។ លុះមើលសព្វគ្រប់ហើយក៏ចុះពីវិហារមកវិញ លោកគូវែរណើរហ្សិណេកល់ និងអស់លោកមន្ត្រីបារាំងទាំងអស់ ក៏លាព្រះសង្ឃនិងបណ្ដាជនជាតិខ្មែរទាំងអស់ មានលោកចៅហ្វាយខេត្ត អ៊ឹម ជាដើម ហើយត្រឡប់ទៅកាន់ក្រុងព្រៃនគរវិញ ។ លោកគូវែរណើរហ្សិណេកល់ ទៅវេលាដែលលោករៀបនឹងត្រឡប់ទៅវិញ លោកបានមានប្រសាសន៍នឹងខ្ញុំថា សូមលោកយកសេចក្ដីក្រាបបង្គំទូលព្រះករុណាជាម្ចាស់ជីវិតផង អំពីដំណើរដែលលោកអញ្ជើញមកកាន់ដែនកូសាំងស៊ីនដូចម្ដេចខ្លះ នឹងអំពីខ្លួនលោកដែលមានអំណរគុណ នឹងព្រះករុណាជាម្ចាស់ជីវិតជាច្រើន ដោយទ្រង់បានចាត់ព្រះសង្ឃ ១ អង្គឲ្យទៅជួយធ្វើការលោកក្នុងដែនកូសាំងស៊ីននេះ ។

កាលក្រោយលោកគូវែរណើរហ្សិណេកល់ អញ្ជើញត្រឡប់ទៅវិញ ម៉ាដឺម៉ូអាហ្សែល ការប៉ីឡែស និងខ្លួនខ្ញុំ មិនទាន់បានត្រឡប់មកភ្នំពេញវិញក្នុងថ្ងៃនោះទេ ព្រោះលោកចៅហ្វាយខេត្ត អ៊ឹម បានសុំឃាត់ឲ្យនៅ ១ ថ្ងៃទៀត ដើម្បីឲ្យបានជួយរំឭកដល់បណ្ដាជនខ្មែរ ទាំងព្រះសង្ឃទាំងគ្រហស្ថ ឲ្យខំប្រឹងសង្វាតរៀនសូត្រ ប្រយោជន៍នឹងឲ្យមានចំណេះវិជ្ជាកល់ខ្លួនឡើងផង ប្រយោជន៍នឹងឲ្យបានព្រះពុទ្ធសាសនាចម្រើនថ្កុំថ្កើងឡើងផង ។

ដល់វេលាម៉ោង ៧ យប់លោកចៅហ្វាយខេត្ត បានឲ្យប្រជុំព្រះសង្ឃ និងគ្រហស្ថនៅទីសាលានោះ លោកអាត់មីនិស្ត្រាទ័រនិងលោកកូឈួយ នៅខេត្តនោះ និងម៉ាដឹម៉ូអាហ្សែល ការប៉ឺឡែស កំអញ្ជើញទៅជួបជុំជាមួយផង ទើបបាននិមន្តខ្ញុំទៅឲ្យនិយាយពន្យល់ និងរំឭកដាស់តឿនតាមផ្លូវធម៌ ក្នុងព្រះពុទ្ធសាសនាខ្លះតាមផ្លូវក្នុងលោកនេះខ្លះ តាមសមគួរដល់កាលវេលា ។

ថ្ងៃសុក្រ ១៣ កើតខែអាសាធ ឆ្នាំម្សាញ់ឯកស័ក ព.ស. ២៤៧២ ត្រូវនឹងថ្ងៃ ១៩ ខែសុយេត ឆ្នាំ ១៩២៩ វេលាម៉ោង ៨ ព្រឹក ម៉ាដឹម៉ូអាហ្សែល ការប៉ឺឡែស និងខ្លួនខ្ញុំ បានចេញពីខេត្តសុកត្រាំងមកវិញ ដោយរថយន្តរបស់រាជការប្រតិកកូពីត័ងដែលតាមផ្លូវកងជី ឡុងឈៀង មាត់ជ្រូក តាកែវ ដែលមកដល់ភ្នំពេញ វេលាម៉ោង ៣ រសៀល ។

(ចប់តែប៉ុណ្ណេះហោង)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀម

( តពីខ្សែទី ៣ នៃឆ្នាំទី ២ )

---

## ភាគទីបី

## អាវាហមង្គលនៃនាងទ្រោបទី

ស្រីអនាថា អាស្រ័យនៅក្នុងរោងនាយស្នូទឆ្នាំង ចាំមើលផ្លូវកូនទាំង ៥ ដែលនាំគ្នាទៅមើលការស្វយម្ពរនាង ទ្រោបទី បុត្រទៅបាត់យូរពេកខុសពេលវេលា នាងក៏ព្រួយក្នុងចិត្ត ក្រែងថាកើតហេតុភេទភ័យឡើងក្នុងស្រុកគេ ខណៈនោះ នាងឮស្នូរសន្ធឹកដើរចូលមកដល់ ដឹកទាំងដៃនាងក្រមុំមួយមកផង សឹងតែងកាយដោយគ្រឿងប្រដាប់ដ៏វិចិត្រ សុទ្ធតែពេជ្រ-និលចិន្ដាព្រោងព្រាយ ខណៈដែលបែរទៅឃើញនាងជាទ្រង់ទ្រូវឆោមឆើតឆាយ សេចក្ដីបីតិត្រេកអរក៏ផ្សាយសព្វសារពាង្គកាយ គ្រាន់តែក្រឡេកទៅឃើញ នាងក៏នឹករឿងរហូត មាតានិងបុត្រក៏សន្ទនាប្រាស្រ័យគ្នាតាមទំនៀម ព្រះរាជកុមារទាំង ៥ ក៏ទូលរៀបរាប់រឿងសិទ្ធិជោគដែលខ្លួនធ្វើការមានថ្វីដៃ ឲ្យនាង ជននី ស្ដាប់ តាំងពីដើមដល់ចុង ។

ឥឡូវនេះ នឹងសម្ដែងអំពីហេតុការណ៍ ដែលប្រព្រឹត្តទៅក្នុងព្រះរាជ-

រាំងក្រុងបញ្ចាល ព្រះរាជ ទ្រុបទ ប្រថាប់ក្នុងបន្ទប់ក្រឡាព្រះបន្ទំតែមួយ ព្រះអង្គ ក្រៅអំពីនោះកំមានអ្នកថ្វាយអ៉ំទផ្ចិត (អ្នកបក់ថ្វាយ) ទ្រង់ជញ្ជីង ជ្រប់ដល់ព្រះគ្រោះរបស់ព្រះអង្គ បន្តិចស្តេចក្រោកឡើងទឹងតាំងធាក់អ្នក នេះអ្នកនោះ ដែលនៅផិតថ្វាយអ៉ំទផ្ចិតក្នុងវេលានោះ ខណៈនោះព្រះ រាជទុរសចូលទៅគាល់ក្នុងបន្ទប់ មានកន្ត្រូវផង់ញញឹមញញៀមរីកពាយ ព្រះរាជាធ្វើព្រះកន្ត្រតឹងថ្មឹងទៅរកទុរស លុះស្ងាប់ព្រះគ្រោធហើយត្រាស់ សួរថា ទ្រៅបទី នៅឯណា អ្នកណាបានទាង ទុកូនសំឡាញ់ឪ-ពុក ព្រះសួរសៀងដែលត្រាស់ចេញមក ញ័រហើយស្អកស្អា ទ្រង់ គង់ស្ងៀមបន្តិចត្រាស់តទៅទៀតថា ឳកូនឪពុក អំពីនេះជាដើមទៅ នាងនោងដើរសូមទានគេចិញ្ចឹមពោះរលមាត់ទ្វារផ្ទះអ្នកដទៃ ទានវត្ថុ ដែលបុគ្គលលះដោយការុណ្យចិត្ត និងប្រាណីនេះឯង ជារាជបណ្ណាការ របស់នាង ការជន ដែលនាងកាន់គ្រេចសូមទានគេនោះ ទុកជាគ្រឿង ប្រដាប់ត្បូងរបស់នាង អនិច្ចា ឪពុកទឹងទ្រាំអត់សេចក្តីវេទនាអស់នេះបាន ឬ កាលឃើញកូនស្រីស្ពាយបោមទៅស្នាដើរសុំទានគេឪពុកបានសាង អកុសលកម្មទុកអំពីកាលណាហ្ន៎ ទើបបានមកទទួលសេចក្តីអវមាន (មើល ងាយ) ដូចនេះ អនិច្ចា ឪពុករម្ងាប់ទុក្ខកង់រឿងនេះមិនបាន ហើយ ព្យាយាមដូចម្តេចៗ រាំកំមិនបាត់ក្រំក្នុង អាពុកប្រឹងអត់សង្កត់ណាស់ ទាស់ តែស្គមទ្រមខ្លួន របស់ដែលផុតវិស័យសតិបញ្ញានឹងកែខៃ ឬអស់ផ្លូវនឹង ដើរហើយ ឪពុកនឹងធ្វើម្តេចបាន ឪពុកតាំងចិត្តថានឹងលើកឲ្យទៅអរជុន

តែព្រះដ៏ធំជាម្ចាស់សួគ៌មកបណ្ដាលឲ្យឃ្លៀងឃ្លាតទៅយ៉ាងដទៃ ឪពុកដឹងច្បាស់ហើយថា ការយំខ្សឹកខ្សួលមិនជាប្រយោជន៍ តែទុក្ខនេះជាមរណទុក្ខរបស់បិតាហើយ បិតាមិនអាចទឹងរម្ងាប់បានដោយឧបាយយ៉ាងណាឡើយ ។

ធ្ឫស្ត-ទយុម័ន ក្រាបទូលដោយសម្ដីដ៏ល្ហែមថា បពិត្រព្រះជនកនាថ សូមព្រះអង្គពូលបន្ទោរបង់នូវសេចក្ដីសោកសៅអស់នេះចេញ អំពីព្រះគោមលចុះព្រះករុណា អរជុនជាអ្នកបាននាងទៅជាប្រាកដហើយ ។

ព្រះពជាមានព្រះអស្សុជលកំពុងហៀរហូរ ក៏ស្វាងថែសដោយពលរបីតក្នុងខណៈនោះ ត្រាស់សួរជាប្រញាប់ថា មែនឬ ឯងដឹងបានយ៉ាងម្ដេច អើឯងនិយាយទៅមើល ។

ព្រះឧរសទូលប្រព្រឹត្តហេតុថា កាលព្រាហ្មណ៍នាំព្រះនាងបង (ព្រះទ្រោបទី) ទៅកាន់ទីសំណាក់ ទូលព្រះបង្គំជាខ្ញុំបានលបតាមទៅមិនឲ្យគេឃើញ លុះគេចូលទៅក្នុងទីសំណាក់របស់គេ ទូលព្រះបង្គំផ្ទៀងត្រចៀកលបស្ដាប់អំពីក្រៅទ្វារ បានដឹងរឿងនេះច្បាស់ ក្នុងកាលដែលនិយាយរៀបរាប់ឲ្យមាតាគេស្ដាប់ ទូលព្រះបង្គំទើបដឹងបានថាព្រាហ្មណ៍ ១ ពួកគ្នា ៥ នាក់ ស្លៀកដណ្ដប់ស្បែកអម្រឹគនោះគឺ បាណ្ឌវកុមារបងប្អូនទាំង ៥ ឬមកគ្គិមកមុខន្តរអាសូរ បាណ្ឌពកុមារនិងមាតាបានសេចក្ដីព្រួយលំបាកជាបំផុត ព្រោះទុរយោធន៍គិតឫស្យាដុតមន្ទីររបស់គេ ដើម្បីឲ្យស្លាប់ក្នុងគំនរភ្លើង តែគ្រោះជា បាណ្ឌពកុមារដឹងខ្លួនបានជាមុន ទើបនាំគ្នារត់

តាមផ្លូវបាតាល រួចអំពីភ័យមក បាននាំគ្នាដើរផ្លូវមកជាមួយនឹងពួកព្រាហ្មណ៍ ទាល់តែមកដល់ក្រុងបញ្ចាលនេះ ព្រះរាជាទ្រង់ជឿជាក់អស់សង្ស័យ ទើបត្រាស់ថា កូនឯងចូលទៅប្រាប់អគ្គមហាសេនាបតី ឲ្យគេទៅសើបសួរយកសេចក្ដីពិតមកឲ្យបាន ។

ខ្ញុំរាជការមួយពួកទទួលរាជឱង្ការហើយ នាំគ្នាដើរសំដៅទៅផ្ទះស្នូនឆ្នាំង មន្ត្រីអំបាលនោះចូលទៅថ្វាយគំនាប់បាណ្ឌពរាជកុមារ ហើយម្នាក់ក្នុងពួកមន្ត្រីដែលទៅនោះ ទូលប្រព្រឹត្តហេតុដល់រាជកុមារដែលបានទ្រោបទី ថា : យើងខ្ញុំនាំគ្នាសម្ដែងសេចក្ដីអំណរដែលលោកមានជ័យការដែលលោកសម្ដែងស្នាដៃក្នុងថ្ងៃនេះ ពួកអ្នកចម្រៀងនឹងចងជាបទកាព្យទុកសម្រាប់សង្គីតប្រគំច្រៀង ពួកចិន្ដកវីរាជប្រាជ្ញពង្សាវតារនឹងចារឹករឿងនេះ ទុកក្នុងពង្សាវតារឲ្យខ្ចាយខ្ចរ និករជាតិទាំងឡាយក៏នឹងមនសិ-ការចាំទុក រហូតកល្បាវសានដោយធនូនិយម កាលក្សត្រិយ៍ទាំងឡាយបាញ់មិនត្រូវនោះ ខត្តិយាធិបតីរបស់យើងព្រួយព្រះហឫទ័យថា ព្រះរាជធីតារបស់ព្រះអង្គ គង់តោងនៅជាលីវសារកែរកគូគ្មានរហូតជីវិត រឿងនេះជាទុក្ខធំគ្របសង្កត់ព្រះហឫទ័យ តើឥឡូវនេះយើងខ្ញុំសូមអរគុណលោកយ៉ាងខ្ពស់ដែលលោកបានកំចាត់មេឃមីរ ពោលគឺសេចក្ដីកង្វល់ដ៏ធំសឹងគ្របសង្កត់ព្រះហឫទ័យព្រះករុណាចេញទៅបាន ក្នុងវេលានេះយើងខ្ញុំយល់ឃើញថា ក៏ល្មមនាំមកបញ្ចេញថែកគ្នាស្ដាប់បាន ហើយមិនមែនជាការល្មើស ក្នុងការរក្សាសេចក្ដីសម្ងាត់ក្នុងព្រះហឫទ័យនោះទេ គឺអំពីដើម

ឃើញការសម្រេចផលសមប្រាថ្នា ទូវរបស់សឹងគិតទុកមកជាយូរយារ ហើយនោះ ។

កាលពួកខ្ញុំរាជការបានស្តាប់ដូចនោះ ក៏ក្រោកឡើងព្រមគ្នា ថ្វាយគំនាប់ឱនលំទោនហើយក៏លាទៅ សេចក្តីបំណងរបស់គេវេលានេះក៏សម្រេចពិតឥតសង្ស័យ មកលសួរយកការពិតបាន តាមដែលម្ចាស់ជីវិតប្រើមក គេក៏រីករាយនាំគ្នាត្រឡប់ទៅក្រាបទូលប្រព្រឹត្តហេតុដល់ព្រះរាជាវិញថា ការដែលត្រាស់ប្រើទៅនោះ ឥឡូវសម្រេចដូចព្រះហឫទ័យបំណងហើយ ។

កាលបានសេចក្តី តាមដែលត្រាស់ប្រើឲ្យទៅស៊ើបក្នុងជាន់ក្រោយនោះហើយ គ្រានោះត្រាស់ឲ្យមានមហោស្រពក្នុងព្រះរាជមន្ទីរ ទឹងត្រាស់ឲ្យទៅអញ្ជើញបាណ្ឌវកុមារទាំង ៥ ចូលមកគាល់ មានការទទួលតាមខត្តិយប្រវេណី ក្នុងទីសម្រាប់ទទួលមន្ត្រី ទ្រង់ពូលទៅឧបឧរសប្រ-សា និងបងប្អូនទាំង ៤ អង្គ ទៀតតាមលំដាប់ ត្រាស់សុន្ទរកថាទទួលសម្ពន្ធមិត្រមេត្រី ទឹងទទួលប្រកាន់សព្វភ័យទាំងពួងក្នុងរាជធានីរបស់ព្រះអង្គ មិនឲ្យមានមោះម្ហះការបាន ។

លំដាប់នោះទ្រង់ឲ្យចាត់ការស្វយម្ពរវិវាហមង្គល រាជធីតាទ្រៅប-ទី សមស័ក្តិ សមកិត្តិយស នៃខត្តិយធីតាគ្រប់ប្រការ ទាំងឲ្យមានការល្បែងលេងតាមទំនៀមវិវាហសម្ពោធ ពួកបាណ្ឌពកុមារក៏ដោះគ្រឿង

ប្ដូមចេញ នៅជាសុខក្នុងអារក្ខារបស់ព្រះចៅបញ្ចាលរាជ ជារាជសម្ពន្ធមិត្រដ៏ប្រសើរស្មើចិត្តនោះហោង ។

# ភាគ ទី បួន

## ទីប្រជុំរដ្ឋមន្ត្រី

កាលក្រោយពិធី អភិសេកសមរស និងអាជុនរាជកុមារសម្រេចហើយ បាណ្ឌវក្សត្រិយ៍ក៏នៅជាសុខក្នុងអំណាចរក្សានៃបញ្ចាលរាជ ការគ្រប់គ្រងរក្សាដូចនេះ ជាទីត្រូវហឫទ័យបាណ្ឌវក្សត្រិយ៍ណាស់ នឹងឫមអង្គដើរហើរទៅឯណាដូចអំពីដើមទៀតពុំបានឡើយ ព្រោះទុរយោធន៍បានឃើញហើយចាំបានជាប្រាកដថា រាជកុមារគម្បាលនេះនៅមានជីវិតរស់នៅ ទុរយោធន៍គង់ជាភ្ញាក់ខ្លួនមិនតិចដែរ មកឃើញបាណ្ឌវក្សត្រិយ៍នៅមានជីវិតរស់នៅក្នុងលោក ហើយគង់នឹងខ្វល់ក្នុងហឫទ័យជាបំផុត ដែលមកឃើញអាជុនមានជ័យ បាននាងក្សត្រីបញ្ចាល ជាបាទបរិចារិកា នោះចិត្តឫស្យាររបស់ទុរយោធន៍គង់ឈួលឡើងរកទីបំផុតគ្មាន ដែលមកឃើញព្រះញាតិ ដែលព្រះអង្គធ្វើឧបាយនឹងបំផ្លាញឲ្យវិនាសក្នុងអគ្គីនោះ មកចងស្ពានមេត្រីនឹងព្រះចៅទ្រុបទ ដែលជាសត្រូវនឹងព្រះអង្គតាំងពីកាលណាមកហើយ ។

មានការប្រជុំធំនៅក្រុងហស្តិនបុរ ធ្រឹតរាស្ត្រប្រថាប់លើរាជបល្ល័ង្ក មានរាជបរិពារឈរព័ទ្ធជុំវិញត្រៀប បីដូចជាផ្កាយចោមរោមព្រះចន្ទស្វាត់

សម្ដេចព្រៀប ប្រុងស្តាប់សព្វព្រះរាជតម្រាស់ ព្រះរាជាក៏ទ្រង់ក្រោកឡើងឈរ មានព្រះរាជឱង្ការសីហនាទត្រាស់ថា ៗ

ម្នាលមន្ត្រីទីប្រឹក្សាទាំងសម្លាយដែលមកសន្និបាតក្នុងទីនេះ សុទ្ធតែជាអ្នកដែលយើងទុកចិត្តក្នុងរាជការផែនដី អ្នកទាំងឡាយជាគោលសិលារបស់ប្រទេស អាណាចក្ររបស់យើងដែលនឹងតាំងនៅបាន ក៏ព្រោះអាស្រ័យអ្នកទាំងឡាយជាភ្នែក ជាប្រមុះសេចក្តីចម្រើនរុងរឿងថ្កើងកើត នឹងសេចក្តីសុខសម្រាន្តរបស់រាស្ត្រដែលនឹងវឌ្ឍនាគតទៅបាន ក៏ព្រោះអា-ស្រ័យអ្នកទាំងឡាយ សេចក្តីសត្យសុចរិតនឹងផែនដីនៃអ្នករាល់គ្នា ក៏គ្មានផ្លូវឲ្យវង្វៀស សេចក្តីដែលអ្នកទាំងឡាយភក្តីនឹងយើង ក៏គ្មានមន្ទិលមួយហ្មង់សូម្បីប៉ុនល្អងធូលី របស់នោះហ្មង់ក្នុងរាគីក៏គ្មានចូលមកលាយឡំក្នុងសេចធាតុពោលគឺសេចក្តីភក្តីនេះឡើយ យើងឲ្យហៅអ្នកទាំងឡាយមកប្រជុំក្នុងគ្រានេះ ដើម្បីឲ្យអ្នករាល់គ្នាជួយពិគ្រោះបញ្ហាមួយ ១ ដែលតែអំពីវិចារណញ្ញាណរបស់យើងតែម្នាក់ឯង មិនអាចនឹងទំពាឲ្យបែកទៅបានសូមប្រើជាញាណរបស់អ្នករាល់គ្នាចូលជួយទំពាយើង សូមឲ្យអ្នកទាំងអស់ចូលសម្តែងសេចក្តីភក្តីដល់យើង នឹងចូលបំពេញបំរោះដល់ផែនដីក្នុងគ្រានេះម្តងទៀត អ្នកទាំងឡាយក៏ជ្រាបហើយថា ពួកបាណ្ឌពបានចងសម្ពន្ធមេត្រីនឹងព្រះរាជាទ្រុបទះ ដែលជាសឹកសត្រូវនឹងយើង ដើម្បីនឹងរំលាយលាងអមិត្រអ្នកគិតប្រទូស្តរាយ ឲ្យចេញពាកបារាំពោលគឺភយន្តរាយ អ្នកទាំងឡាយនឹងគិតធ្វើដូចម្តេចស្រួល ៗ

ទុរយោធន៍ក្រោកឡើងឈរ ពោលតែបញ្ហាជាដំបូងថា សេចក្តីយល់របស់ទូលបង្គំជាខ្ញុំក្នុងរឿងនេះ គឺត្រូវឲ្យសូកពួកសេនាបតីព្រះចៅទ្រុបទ ធ្វើឲ្យបែកសាមគ្គីក្នុងរវាងពួកគេឡើងនេះជាឧបាយ ១ ។ ទូលបង្គំជាខ្ញុំនៅមានឧបាយក្នុងចិត្តមួយយ៉ាងទៀត ដែលនឹងឲ្យផលវិសេសជាង១មុន គឺត្រូវរិះរកទោសដំលាមក មកបាចប្រឡាក់នាង ទ្រោបទី ឲ្យនាងនិយាយមិនចេញកែខ្លួនមិនរួច ។ នេះជាហេតុធ្វើឲ្យពួកបាណ្ឌវក្រោធមួហ្មងហើយ លះលែងនាងចោល អំពីនោះមិត្រភក្តិរវាងពួកបាណ្ឌវ និងបញ្ចាលរាជក៏នឹងដាច់អំពីគ្នាទៅឯង ការដែលត្រូវធ្វើតអំពីនោះទៀត គឺដាក់ថ្នាំបំពុល ក៏ឬ យកព្រំឲ្យស្លាប់បង់ ប៉ុណ្ណេះក៏អស់រឿងអំពល់ចិត្តយើងទៅហើយ ទុរយោធន៍អង្គុយចុះ កណិកក្រោកឡើងឈរថ្លែងមតិ ។

សូមទ្រង់អភ័យដល់ទូលព្រះបង្គំជាខ្ញុំ ក្នុងការដែលមានសេចក្តីឃើញមិនដូចទ្រង់ទុរយោធន៍ ដែលជាទីសំឡាញ់របស់យើង ទូលព្រះបង្គំឃើញមានថ្នាំតែមួយមុខ គឺអាស្រ័យកម្លាំងទាហានដ៏រឹងប៉ឹងរបស់យើងឲ្យបញ្ជូនទាហានទៅធ្វើសង្គ្រាមនឹងព្រះចៅ ទ្រុបទ ជាយ៉ាងឆាប់ ទូលព្រះបង្គំជឿថា កងទ័ពរបស់គេទុព្វលភាព គង់នឹងតបតល់កម្លាំងទាហានរបស់យើងមិនបាន ដែលនឹងលើកកម្លាំងទៅយាយីគ្រានេះ ត្រូវចាត់-ការដោយរួសរាន់ ដើម្បីកុំឲ្យព្រះក្រិស្ណ ព្រះរាជាគុជរាត មានឱកាសលើកម្លាំងមកជួយគេបាន ។

លំដាប់នោះ ព្រះចៅធ្ឫតរាស្ត្រត្រាស់សួរ គឹស្ន ក្សត្រិយ៍ដ៏ពកើ ឯងមានយោបល់យល់ឃើញដូចម្តេច គឹស្ន ថ្វូងថា កាលបើព្រះករុណាសុំសេចក្តីឃើញរបស់ទូលព្រះបង្គំ ទូលព្រះបង្គំ ក៏ត្រូវពោលតែពាក្យពិត តែបុរាណលោកថា (ពាក្យពិតវែងស្វែង) ទូលព្រះបង្គំយល់ឃើញថា តាមសិទ្ធិនៃរាជប្រវេណី យុធិស្ឋិរជារជ្ជទាយាទ តាមច្បាប់ត្រូវបានរាជសម្បត្តិ បើព្រះករុណាមិនសព្វព្រះហឫទ័យនឹងលះរាជសម្បត្តិទាំងមូលឱ្យគេសោត ក៏គួរបែងផែនដីឱ្យគេពាក់កណ្តាល យុត្តិធម៌នឹងសេចក្តីពិតត្រូវឱ្យទ្រង់ប្រតិបត្តិការក្នុងរឿងនេះដូចនេះ បើទ្រង់កើបកោយយកទ្រព្យសម្បត្តិទាំងភាគដែលគេត្រូវបានមកសោត ទូលបង្គំព្យាករណ៍ទុកក្នុងវេលានេះថា សេចក្តីវិនាសលិចលង់អាណាចក្ររបស់ទ្រង់ នឹងមកដល់ក្នុងមិនយូរ សេចក្តីលោភលន់ហួសប្រមាណ នឹងនាំនូវសេចក្តីវិនាសយ៉ាងធំមកឱ្យដល់ប្រយូរវង្សរបស់ទ្រង់ ដំណឹងដែលខុសព្រះករុណាគិតប្រទុស្តនឹងដុតបងប្អូនទាំងរស់នោះ ល្បីរហូតទៅក្រៅអាណាចក្រកុរុ អ្នកស្រុកខាងក្នុងខាងក្រៅរាជអាណាចក្រពោលខ្លាំងខ្ចប់ថា ទុរយោធន៍ជាអ្នកគិតប្រទុស្តរាយទំលាយព្រះញាតិ ៗ

កណិក្រោកឈរឡើងជាគម្រប់ពីរដង ដើម្បីបរិយាយវចនវោហាររបស់គិស្ន គេនិយាយថា ចិត្តរបស់គិស្ន ប្រកបដោយឆន្ទាគតិ ភ្នែករបស់គិស្នងងឹតក្នុងយុត្តិធម៌វិចារណញាណរបស់គិស្ន ឃើញឆោះទៅក្នុងផ្លូវខុស គិស្ន មានពេតាពាធឯណានិមួយមកបិទបាំង ញុំាងទស្សន-

ញាណរបស់គេឲ្យវិកលទៅ រឿងនេះជាមុខក្រសួងរបស់ទីប្រឹក្សា ទីប្រឹក្សាគោរពតបបញ្ហាឲ្យចិតដិតទៅតែម្ដង ដោយទឹកចិត្តដ៏ត្រជាក់ មិនត្រូវញញើតនឹងគ្រឿងខ្លាំងខ្ទប់ឯណាទិមួយ សម្ដីទីប្រឹក្សាអ្នកប្រកបដោយសេចក្ដីប្រហែសធ្វេស និយាយចេញមកឃើញថា ខ្សត់វិចារណញ្ញាណមិនគិតឲ្យដុំដិតជ្រងជ្រោយសិន រមែងនាំសេចក្ដីវិនាសមកឲ្យប្រទេស ។

ទោណាចារ្យឃាត់កណ៌ថា ឈប់សិនទៅកណ៌អើយ ឈប់រលាស់អណ្ដាត ដែលប្រកបទៅដោយសេចក្ដីអួតទៅសិនទៅ អ្នកមិនបង្អង់និយាយ ទាល់តែសេចក្ដីវិនាសធ្លាក់មកលើខត្តិយវង្សរបស់យើងទៅឬ អាការធ្ងន់ណាស់ព្រះគុណអើយ កុំម៉្លោះពេក វិទូរក្រោកឈរឡើងពោលទទឹងទាស់នឹងមតិទុរយោធន៍ថា ។

មុខងារនោទីរបស់ខ្ញុំ បង្គាប់ខ្ញុំឲ្យពោលចេញមកតាមសេចក្ដីពិតត្រង់ក្នុងចិត្ត ផលក្នុងទីបំផុតនឹងបង្កើតឡើងដូចម្ដេច ទុក១អន្លើ ថាបើបណ្ដោយឲ្យករណីហេតុដំណើរទៅដូចនេះ ក្នុងពេលមិនយូរ គង់នឹងប្រទះអានិដ្ឋារម្មណ៍ជាមិនខាន ព្រះនាមកិត៌ិបនៃវង្សក្សត្រិយរបស់យើងនឹងសាបសូន្យទៅ ព្រោះហេតុនោះគំនិតរបស់យើងខ្ញុំ ក៏គឺនឹងឲ្យផ្សះផ្សាសេចក្ដីបែកសាមគ្គីរវាងព្រះញាតិវង្ស ដោយឧបាយឯណាទិមួយដ៏ប្រពៃ តាមផ្លូវយុត្តិធម៌ ។

ការប្រឹក្សាគ្នាឈប់ស្ងេះតែប៉ុណ្ណោះ ព្រះចៅធ្ឫតរាស្ត្រ ក៏ប្រកាសកាត់សំនួន ជាពាក្យដាច់ខាតចេញមកថា ត្រូវទៅទទួលបាណ្ឌវក្សត្រិយ

ដែលត្រូវនិរទេស ត្រឡប់មកកាន់ព្រះនគរវិញ យើងនឹងប្រគល់ផែនដីហស្តិនបុរឲ្យពាក់កណ្តាល ឲ្យបងប្អូនទាំង ៥ សេពសោយសម្បត្តិតាមខត្តិយប្រវេណី ។

លំដាប់នោះ ទើបទ្រង់ចាត់ឲ្យរាជទូតនាំរាជសាសន៍ទៅកាន់ក្រុងបញ្ចាល ដើម្បីនឹងអញ្ជើញយុធិស្ឋិរព្រមទាំងប្អូនបួននាក់ត្រឡប់មកព្រះនគរ កាលរាជទូលអម្បាតនេះទៅដល់ក្រុងបញ្ចាល នាំគ្នាចូលគាល់ក៏ប្រទះគ្នានឹងបាណ្ឌវកុមារ កំពុងគាល់សន្ទនារីករាយ ជាមួយព្រះចៅទ្រុបទ ។

ព្រះរាជទ្រុបទ ត្រាស់ព្រះសូរសៀងយ៉ាងអាណោចអាធមថា យុ-ធិស្ឋិរ គ្មានរឿងអ្វីក្នុងពង្សាវតារបស់លោក នឹងដូចរឿងរបស់អ្នកទេ មុខគួរវេទនាអីម៉្លេះ ដែលព្រះញាតិរបស់អ្នកត្រឡប់ទៅជាសត្រូវ ជាគូបងពៀរវេរនឹងគ្នាដូចនេះ ។

យុធិស្ឋិរពោល អារឿងលាភ រឿងអំណាច ទូលព្រះបង្គំមិនចង់ឃើញមុខវា វាធ្វើឲ្យបងប្អូនទាស់ទែងគ្នា ឪពុកនិងកូនទាស់គ្នា ទ្រព្យសម្បត្តិ អំណាច ស្ត្រី របស់ ៣ មុខនេះ ជាមារសម្រាប់ផ្តាញ់មនុស្ស យើងឲ្យវិនាសហិនហោចទៅ ។

ព្រះរាជាទ្រុបទ ឡើងព្រះភក្ត្រប្រាលដោយលោហិត ត្រាស់ថា យើងសុំធ្វើពាក្យផ្តាំជាប្រកាសទុកក្នុងទីនេះ ថាបើអ្នកឯងមិនបានចំណែកព្រះនគរដោយស្រួលសោត យើងនឹងជួយអ្នកឯងដោយកម្លាំងអាវុធ ។

ខណៈនោះ អ្នកភ្នាក់ងារមុខក្រសួងនាំទូតចូលទៅគាល់ ទូតរម្យាល នោះចូលទៅក្រាបបង្គំព្រះកត្រ្តីក្រាបទូលថា ខត្តិយាធិបតីដ៏ជាម្ចាស់ របស់ទូលព្រះបង្គំជាខ្ញុំ ត្រាស់បញ្ជាឲ្យនាំពារដ៏មានដ៏ជាមង្គលមកក្រាប ទូលព្រះអង្គឲ្យទ្រង់ជ្រាប ដ្បិតព្រះរាជាមានព្រះហឫទ័យសោមនស្ស ណាស់ ដែលមកឃើញសេចក្តីប្រួមគ្នារវាងរាជត្រកូលទាំងពីរ គឺបណ្តូ និង បញ្ចាល តែព្រះរាជាដ៏ជាប្រធាននៃកុរុរដ្ឋមានព្រះរាជហឫទ័យបំ ណងនឹងឃើញមុខកត្រ្តីព្រះកាត់ណៃទាំងប្រាំ ព្រះរាជជននីសោតក៏ចង់ យល់ព្រះកត្រ្តីយុវតីស្រីសុណិសា ប្រជាជនត្រៀមព្រមគ្នាហើយ ដើម្បី នឹងទទួលស្តេច ។

ព្រះរាជាទ្រុបទមិនសព្វព្រះហឫទ័យក្នុងរឿងដែលបាណ្ឌវកុមារនឹង ត្រឡប់ទៅក្រុងហស្តិនបុរវិញ តែនឹងទ្រង់ហាមឃាត់សោត មើល ទៅជាការមិនគួរ ក្នុងទីបំផុតក៏ទ្រង់អនុញ្ញាតតាមសុំ ។

ពាណ្ឌពកុមារ ព្រមដោយព្រះជននីនឹងនាងទ្រៅបទី ក៏ រៀបចំរាជដំណើរ ស្តេចដើរផ្លូវទៅកាន់ក្រុងហស្តិនបុរ មានទាហាននឹង រាជបរិវារជាក្បួនហែហម នឹងមានក្មេងត្រែសង្ខក្លស្រត្រ្តីប្រគំសូរសព្ទ ទ្រហឹងអឹងកង់ទៅតាមមគ្គវិថី ។

កាលមកដល់ក្រុងហស្តិនបុរ មន្ត្រីខ្ញុំរាជការអ្នកធំចេញមកទទួល នៅទ្វារព្រះនគរ រាស្ត្រនិករទាំងពួងក៏ជ្រើមជ្រួលបបួលគ្នាមកទទួលស្តេច ជាទីស្រឡាញ់របស់គេ ដោយបីតិដ៏មានកម្លាំងសឹងពុំអាចនឹងទប់ដើងឲ្យ

ឲ្យនឹង លុះឮសូរកាំភ្លើង ទឹង ទឹង ដែលគេបាញ់ថ្វាយគំនាប់ខ្ទរទាំងពសុធា អ្នកនគរក៏ចូលចិត្តបានថា បិយក្សត្រិយ៍របស់គេចូលមកក្នុងខេត្តព្រះនគរហើយ សេចក្តីរីករាយរបស់រាស្ត្រទប់ដើងមិនទឹង បណ្តាស្ត្រីប្រុស ចាស់ក្មេង តូចធំ ស្រោកស្រហូរហៀរពេញមក ដើម្បីឃើញបាណ្ឌវក្សត្រិយ៍ ។

(មានតទៅទៀត)